សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា
Cambodian Human Rights and Development Association
ផ្ទះលេខ៣ ផ្លូវ១៥៨ ឧកញ៉ាត្រឿងកាង សង្កាត់បឹងរាំង ខណ្ឌដូនពេញ ភ្នំពេញ, № 3, St 158 Oukhna Troeung Kang, Boeng Raing, Daun Penh, Phnom Penh.
Tel: (+855-23) 218 653 / 210 518 / 990 544 P.O. Box: 1024 P.O, Box 20 at CCC, E-mail: info@adhoccambodia.org
Website: www.adhoccambodia.org, Facebook Page: www.facebook.com/adhoccam, Twitter: www.twitter.com/adhoccam
សមាគមអាដហុក
ADHOC

# ដំណឹងជ្រើសរើសបុគ្គលិក

**សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា** (**អាដហុក**) គឺជាអង្គការមិនមែនរដ្ឋាភិបាលឯករាជ្យ-អព្យាក្រឹត ដែលមិនរកផលចំណេញ និងមិនស្ថិតក្រោមឥទ្ធិពលនយោបាយរបស់គណបក្សនយោបាយណាមួយ ហើយធ្វើការងារដើម្បីសង្គមមួយ ដែលគោរពសិទ្ធិមនុស្ស និងច្បាប់ តាមរយៈការបង្កើនចំណេះដឹងផ្នែកសិទ្ធិមនុស្ស និងច្បាប់ដល់ប្រជាពលរដ្ឋធ្វើយ៉ាងណាឲ្យគាត់យល់អំពីសិទ្ធិមនុស្ស និងចេះការពារសិទ្ធិដោយខ្លួនឯង។ **សមាគមអាដហុក** ត្រូវបានបង្កើតឡើងនៅចុងឆ្នាំ ១៩៩១ ដែលមានការិយាល័យកណ្ដាលនៅទីស្នាក់ការភ្នំពេញ និងការិយាល័យខេត្ត-រាជធានី ចំនួន២១។

យោងតាមតម្រូវការជាចាំបាច់របស់ **សមាគម** នៅក្នុងពេលបច្ចុប្បន្ននេះ **សមាគមអាដហុក** សូមជូនដំណឹងដល់សាធារណៈជនទាំងអស់ឲ្យបានជ្រាបថា សមាគមត្រូវការជ្រើសរើសបុគ្គលិក **ចំនួន ៤ រូប ប្រចាំខេត្ត កំពត ក្រចេះ កោះកុង ព្រៃវែង** ដែលមានតួនាទីជា**មន្ត្រីអង្កេត** ដើម្បីទទួលភារកិច្ច និងការទទួល ខុសត្រូវដូចខាងក្រោម៖

## ភារកិច្ច និងការទទួលខុសត្រូវ

- ចុះអង្កេត តាមដាន និងអន្តរាគមន៍ករណីរំលោភសិទ្ធិស្ត្រី និងកុមារ
- ប្រមូលព័ត៌មាន និងសរសេររបាយការណ៍ ដែលអង្កេតជូនប្រធានផ្នែកអង្កេត នៅស្នាក់ការកណ្ដាល
- ទទួលពាក្យបណ្ដឹងជួយសរសេរពាក្យបណ្ដឹងជូនជនរងគ្រោះនិងប្រឹក្សាយោបល់ ផ្នែកច្បាប់
- សរសេរលិខិតអន្តរាគមន៍ផ្សេងៗទៅអាជ្ញាធរមានសមត្ថកិច្ច
- ឆ្លើយឆ្លងជាមួយសាព័ត៌មាន
- ជួយសម្របសម្រួលការងារ Social Worker (ចុះជួប វាយតម្លៃ ស្ថានភាពជនរងគ្រោះ និងគ្រួសារ, តាមដានស្ថានភាពជនរងគ្រោះ, ទំនាក់ទំនង ស្វែងរកជំនួយពីអង្គការដៃគូ)
- ធ្វើកិច្ចតែងការ ចុះបើកវគ្គ វេទិកាសាធារណៈ និងរៀបចំកម្មវិធីជួបជាមួយក្រុមគោលដៅ
- ទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន មន្ត្រីតុលាការ និងសហគមន៍
- ធ្វើលិខិតអន្តរាគមន៍ដែលពាក់ព័ន្ធ (ករណីចាំបាច់)
- ធ្វើរបាយការណ៍ប្រចាំខែជូនប្រធានកម្មវិធី
- ចូលរួមកម្មវិធីផ្សេងៗ ជាមួយអាជ្ញាធរ និងអង្គការដៃគូ តាមការចាត់តាំងរបស់អ្នកសម្របសម្រួល

- ក្នុងករណីចាំបាច់ អ្នកសម្របសម្រួលខេត្ត ឬប្រធានផ្នែក អាចផ្តល់តួនាទី/ភារកិច្ចលើសពីការចែងខាងលើ

## **បេក្ខជន/បេក្ខនារីត្រូវមានលក្ខណៈសម្បត្តិដូចតទៅ**

- មានអាយុចាប់ពី ២៥ ឆ្នាំឡើងទៅ
- មានកំរិតវប្បធម៌ថ្នាក់បរិញ្ញាប័ត្រផ្នែកច្បាប់ ឬសញ្ញាប័ត្រដែលមានតម្លៃស្មើរ
- មានបទពិសោធន៍ធ្វើការងារជាមួយអង្គការសិទ្ធិមនុស្សជាតិ អន្តរជាតិ ពីរឆ្នាំឡើងទៅ
- មានភាពស្មោះត្រង់ និងគួរឱ្យទុកចិត្ត និងក្រមសីលធម៌ការងាររឹងមាំ
- មានសេចក្តីក្លាហាន និងចំណេះដឹងផ្នែកសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ
- ចេះភាសាខ្មែរស្ទាត់ជំនាញក្នុងការនិយាយ និងសរសេរ
- មានសមត្ថភាពអាចនិយាយ និងសរសេរជាភាសាអង់គ្លេស
- មានជំនាញទំនាក់ទំនងផ្ទាល់មាត់ និងសរសេរបានប្រកបដោយប្រសិទ្ធភាព
- ជំនាញសរសេររបាយការណ៍យ៉ាងល្អ និង
- មានជំនាញខាងកុំព្យូទ័រ Microsoft Word, Excel, Internet and E-mail.

## **ប្រាក់ខែ និងល័ក្ខខ័ណ្ឌ**

សមាគមអាដហុក នឹងអាចផ្តល់ប្រាក់ខែសរុបចំនួនចន្លោះពី ៣៨៥-៤០០ ដុល្លារ (មានបូកអត្ថប្រយោជន៍ និងប្រាក់ឧបត្ថម្ភបន្ថែម)។ យើងកំពុងស្វែងរកបេក្ខជន ដែលមានឆន្ទៈក្នុងការបំពេញតួនាទីនេះ យ៉ាងតិចចាប់ពីមួយឆ្នាំឡើងទៅ។

បេក្ខជន/បេក្ខនារី ដែលមានចំណាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូប មកការិយាល័យរដ្ឋបាល តាមអាស័យដ្ឋានផ្ទះលេខ ៣ ផ្លូវ១៥៨ ឧកញ៉ាត្រឿងកាង សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឬតាមរយៈ៖ 023 218 653 / 086 407 666 និង អ៊ីម៉ែល recruitment@adhoccambodia.org ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ និងផុតកំណត់ទទួលពាក្យត្រឹម **ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង ៥ : 00 ល្ងាច**។

**សមាគមអាដហុក គឺអង្គការមិនមែនរដ្ឋាភិបាលដែលនិយោជិកទាំងអស់មានឱកាសស្មើគ្នា។ ស្ត្រីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ជនជាតិភាគតិច និងជនពិការភាព ត្រូវបានលើកទឹកចិត្តឱ្យដាក់ពាក្យស្នើសុំមុខតំណែងនេះ។**